# ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងឧស្សាហកម្ម និងសិប្បកម្ម
Ministry of Industry & Handicraft
លេខ: ១០៧៣ MIH / 2014

រាជធានីភ្នំពេញ, ថ្ងៃទី ១០ ខែ មិថុនា ឆ្នាំ ២០១៤

**គោរពជូន**

**-ឯកឧត្តមទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម**

**-ឯកឧត្តមរដ្ឋមន្ត្រីក្រសួងសុខាភិបាល**

**-ឯកឧត្តមរដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ**

**-ឯកឧត្តមរដ្ឋមន្ត្រីក្រសួងរ៉ែ និងថាមពល**

**-ឯកឧត្តមប្រធានវិទ្យាស្ថានស្តង់ដារកម្ពុជា**

**-ឯកឧត្តមប្រធានមជ្ឈមណ្ឌលមាត្រាសាស្ត្រជាតិ**

**-ឯកឧត្តមអគ្គនាយករដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញ**

**កម្មវត្ថុ ៖** សំណើសុំអញ្ជើញអ្នកជំនាញផ្នែកមន្ទីរពិសោធន៍ ផលិតផល និងសេវាកម្មនានា មកចុះបញ្ជីនៅនាយកដ្ឋានវាយតម្លៃទទួលស្គាល់។

**យោង ៖** -ព្រះរាជក្រមលេខ នស/រកម/០៦០៧/០១៣ ចុះថ្ងៃទី២៤ ខែមិថុនា ឆ្នាំ២០០៧ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីស្តង់ដារកម្ពុជា

-អនុក្រឹត្យលេខ ៥៧៥ អនក្រ.បក ចុះថ្ងៃទី២៤ ខែធ្នូ ឆ្នាំ២០១៣ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងឧស្សាហកម្ម និងសិប្បកម្ម។

តបតាមកម្មវត្ថុ និងយោងខាងលើ ខ្ញុំសូមជម្រាបជូន **ឯកឧត្តម** ជ្រាបថា ៖ ច្បាប់ និងអនុក្រឹត្យខាងលើ ក្រសួងឧស្សាហកម្ម និងសិប្បកម្មដែលមាននាយកដ្ឋានវាយតម្លៃទទួលស្គាល់ នៃអគ្គនាយកដ្ឋានឧស្សាហកម្មជាសេនាធិការ បានរៀបចំធ្វើការងារចេញវិញ្ញាបនបត្រចុះបញ្ជីវាយតម្លៃទទួលស្គាល់ និងវិញ្ញាបនបត្រវាយតម្លៃទទួលស្គាល់ដល់អង្គភាពវាយតម្លៃភាពអនុលោម មន្ទីរពិសោធន៍ធ្វើតេស្ត ឬក្រិតខ្នាត អង្គភាពបណ្តុះបណ្តាលសម្រាប់ការវាយតម្លៃភាពអនុលោម រូបវន្តបុគ្គលណាមួយដែលមានលក្ខណៈសម្បត្តិដើម្បីអនុវត្តការវាយតម្លៃភាពអនុលោម អធិការកិច្ច និងសេវាកម្មនានា ដើម្បីចូលរួមឲ្យទាន់ពេលវេលានៃកិច្ចដំណើរការសហគមន៍សេដ្ឋកិច្ច



ក្រសួងឧស្សាហកម្ម និងសិប្បកម្ម
៤៥ មហាវិថីព្រះនរោត្តម
សង្កាត់ផ្សារថ្មី ៣ ខណ្ឌដូនពេញ
ភ្នំពេញ ១២២០៥ ( ព្រះរាជាណាចក្រកម្ពុជា

ខុទ្ទកាល័យឯកឧត្តម ទេសរដ្ឋមន្ត្រី
ទូរស័ព្ទលេខ: (៨៥៥ ២៣ ២១១ ៧៧៥
ទូរសារលេខ: (៨៥៥ ២៣ ៤២៨ ២៦៣
អ៊ីមែល: mih.smcabinet@gmail.com

អាស៊ាននៅឆ្នាំ២០១៥ ខាងមុខ។ ដោយសារការងារនេះទាមទារជាចាំបាច់នូវការចូលរួមពីអ្នកជំនាញលើផ្នែកមន្ទីរពិសោធន៍ ផលិតផល និងសេវាកម្មនានា ដែលមានបទពិសោធន៍លើការងារជំនាញនីមួយៗយ៉ាងតិចចំនួន ៥ឆ្នាំឡើង មកចុះបញ្ជីនៅនាយកដ្ឋានវាយតម្លៃទទួលស្គាល់ ដើម្បីត្រៀមបណ្តុះបណ្តាលទៅជាអ្នកវាយតម្លៃទទួលស្គាល់ជាតិ និងអន្តរជាតិ (National and International Assessors)។

អាស្រ័យហេតុនេះ សូម **ឯកឧត្តម** មេត្តាបញ្ជូនមន្ត្រីដែលមានជំនាញតាមផ្នែកខាងលើមកបំពេញបែបបទនៅនាយកដ្ឋានវាយតម្លៃទទួលស្គាល់ តាមការគួរ។

សូម **ឯកឧត្តម** ទទួលនូវការគោរពរាប់អានដ៏ស្មោះ ពីខ្ញុំ។

**ទេសរដ្ឋមន្ត្រី**

**រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម និងសិប្បកម្ម**

**ចម ប្រសិទ្ធ**